**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គិសនីកម្ពុជា**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ: ....៧៦២..... PC.អក

# សេចក្តីជូនដំណឹង
## ស្តីពី

ការអញ្ជើញចូលរួមដេញថ្លៃ ថ្លៃឯកតាសេវាពលកម្មសាងសង់បណ្តាញអគ្គិសនី ជូន អតិថិជនធុនធំនិងមធ្យម សម្រាប់អគ្គិសនីខេត្តចំនួន១៤ សម្រាប់ឆ្នាំ២០១៨

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសអ្នកទទួល ថ្លៃឯកតាសេវាពលកម្មសាងសង់បណ្តាញអគ្គិសនី ជូន អតិថិជនធុនធំនិងមធ្យមសម្រាប់អគ្គិសនីខេត្តចំនួន១៤ សម្រាប់ឆ្នាំ២០១៨ ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជាដែលមានអាសយដ្ឋាន អាគារលេខ ២ ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ ចាប់ពី ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៨ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ៖ 023 67 66 007 និង Website : www.edc.com.kh ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹម ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៨ វេលាម៉ោង 14:00 ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋាន ខាងលើ វេលាម៉ោង 15 : 00 ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។ល៕

ថ្ងៃព្រហស្បតិ៍ ៨កើត ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៨
**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**គីម ស៊ីម**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ